# បុណ្យភ្ជុំបិណ្ឌ



និពន្ធដោយ៖ ផាត លក្ខិណា

រូបភាពដោយ៖ សែម រ៉ាស៊ីន




ប៉ាសួរ «តើកូនដឹងទេថា ខែនេះមានពិធីបុណ្យអ្វី?»
«ចាសប៉ា! ពិធីបុណ្យភ្ជុំបិណ្ឌ ដែលមានរយៈពេល១៥ថ្ងៃ ជាពិធីបុណ្យនឹករលឹកសាច់ញាតិ
ដែលបានស្លាប់របស់ជនជាតិខ្មែរ រៀងរាល់មួយឆ្នាំម្តង» រ៉ាណាឆ្លើយ។
«ចុះហេតុអ្វីបានជាកូនដឹង?» ប៉ាបន្តសួរ។



«អូ! តើកូនបានដឹងអ្វីផ្សេងទៀតដែរឬទេ អំពីពិធីបុណ្យភ្ជុំបិណ្ឌ?»
«អត់ទេប៉ា! អ្នកគ្រូបង្រៀនកូនតែប៉ុណ្ណឹង»។
«បាទកូន! អីចឹងចាំប៉ាពន្យល់ប្រាប់ឱ្យកូនស្តាប់។  ពិធីបុណ្យភ្ជុំបិណ្ឌគេប្រារព្ធធ្វើចាប់ពីថ្ងៃទី១រោច
ដល់ថ្ងៃទី១៤រោច ខែភទ្របទ។ អ្នកភូមិនាំគ្នាដាក់បិណ្ឌ ឬកាន់បិណ្ឌ រីឯថ្ងៃទី១៥រោចគេហៅថា ភ្ជុំបិណ្ឌ។



ពិធីបុណ្យភ្ជុំបិណ្ឌសំខាន់ៗមានដូចជា ពិធីសូត្រមន្ត បង្សុកូល បោះបាយបិណ្ឌ ពិធីបំបួសភ្ជុំខ្សាច់និងពិធីសែនលាដូនតាជាដើម។



មនុស្សម្នាច្រើនកុះករយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅឯវត្តមានដូចជា ម្ហូបអាហារ ផ្លែឈើ នំចំណីនិងគ្រឿងសក្ការៈបូជា។



ហើយគេតែងតែផលិតនំខ្មែរមានដូចជា នំអន្សមជ្រូក នំអន្សមចេក នំគម
នំបត់និងនំជាច្រើនមុខផ្សេងទៀត ព្រោះជាទំនៀមទម្លាប់ប្រពៃណីជាតិ»។
«មែនហើយប៉ា កូនចង់ចេះផលិតនំអន្សមជ្រូក ប៉ុន្តែគ្មាននរណាបង្រៀនកូនសោះ»។








«តើការវេចនំអន្សមជ្រូកត្រូវការគ្រឿងផ្សំអ្វីខ្លះដែរប៉ា?»
«បាទកូន! មានដូចជា អង្ករដំណើប សណ្តែកបាយ សាច់ជ្រូក ដូង ស្លឹកចេកនិងខ្សែចំណង»។



«ចុះរបៀបផ្ចិតនំអន្សមជ្រូកវិញ?»
«បាទកូន! ដំបូងកាត់ស្លឹកចេកហាលឱ្យស្រពាប់បន្តិច កាត់ខ្សែចំណងល្មមចង្ហួចយកអង្ករដំណើបឆាជាមួយដូងឱ្យមានក្លិនឈ្ងុយ។
បន្ទាប់មក ស្ងោរសណ្ដែកបាយឱ្យផុយ សាច់ជ្រូកហាន់ជាចង្វាមូលល្មមសមគួរ ប្រឡាក់អំបិល ម្រេច ស្ករនិងខ្ទឹម។



តម្រៀបស្លឹកចេកដាក់អង្ករដំណើប ដាក់សណ្ដែកបាយពីលើ រួចដាក់សាច់ជ្រូក ហើយចងឱ្យស្អាត ដើម្បីស្ងោរកុំឱ្យទឹកចូល ព្រោះវាអាចបែកខូចនំ។
ចំណែករបៀបស្ងោរវិញ យកស្លឹកចេកដាក់នៅបាតឆ្នាំងជាមុនសិន ទើបដាក់នំចូលក្នុងឆ្នាំង ស្ងោរឱ្យពុះខ្លាំង។
ពេលស្រង់នំចេញព្យួរឱ្យខ្សោះទឹក»។



«មុនថ្ងៃភ្ជុំបិណ្ឌ ប៉ានឹងបង្រៀនកូនធ្វើនំអន្សមជ្រូក ដើម្បីកុំឱ្យបាត់បង់ប្រពៃណីជាតិខ្មែរ»។
«ចាសប៉ា! តើប៉ាចេះធ្វើនំអន្សមដែរឬទេ?»
«បាទ ប៉ាចេះតើកូន! យាយទួតរបស់កូនគឺជាអ្នកលក់នំខ្មែរនៅឯខេត្តបាត់ដំបង កាលពីក្មេងប៉ាតែងតែជួយយាយទួតធ្វើនំលក់»។



រ៉ាណាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង!
នាងលាន់មាត់ថា «ប៉ាពិតជាអស្ចារ្យណាស់!
នៅពេលកូនចេះផចនំអន្សមជ្រូក កូននឹងរៀនធ្វើនំផ្សេងៗទៀតហើយកូននឹងបង្រៀនអ្នកជំនាន់ក្រោយបន្ត
ដើម្បីកុំឱ្យបាត់បង់ប្រពៃណីជាតិខ្មែរយើង»។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញនិងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការ(R4C)បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្រប ទៅនឹងកម្មវិធីសិក្សារបស់ក្រសួងនិងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបង្រៀន៖ https://rermork.org/

មូលនិធិផ្តល់ដោយអង្គការTukTukនិងអង្គការសមាគមន៍រ៉ូតារីក្លឹប។

ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកស្ម័គ្រចិត្តនិងបុគ្គលិកទាំងអស់នៅក្នុងអង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C) ដែលបានបង្កើតសៀវភៅនេះឡើងដោយក្តីមេត្តាធម៌។

ទទួលបានព័ត៌មានបន្ថែម

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន